


# វិទ្យាល័យ

## កម្មវិធីសម្រាប់សិស្សានុសិស្សចាប់ពីឆ្នាំទី ១០ ដល់ទី ១២ របស់យើង គឺ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការផ្លាស់ប្តូរជោគជ័យរបស់ពួកគេ ចូលទៅក្នុងពិភពលោកដែលហួសពីច្រកទ្វារសាលារបស់យើង។

នៅក្នុងក្របខណ្ឌដែលមានការសិក្សាខ្លាំងនិងការគាំទ្រខ្ពស់ គ្រូបង្រៀនរបស់យើងជំរុញសិស្សឱ្យជម្នះនូវព្រំដែននៃភាពស្រណុកស្រួលរបស់ពួកគេ ដែលនឹងអភិវឌ្ឍនូវភាពក្លាហាននិងទំនុកចិត្តរបស់ពួកគេ ដើម្បីគ្រប់គ្រងលើបញ្ហាប្រឈមនានាក្នុងការសិក្សា ការងារ និងជីវិតជាពេលខាងមុខ។យើងផ្តល់តម្លៃលើការគិតបែបត្រិះរិះពិចារណានិងឯករាជ្យ ក៏ដូចជាខិតខំកសាងទំនុកចិត្តលើខ្លួនឯងដល់សិស្សានុសិស្សទាំងអស់របស់យើង ដែលមានសារៈសំខាន់ណាស់ចំពោះសុខុមាលភាពរបស់យុវជនដែលកំពុងផ្លាស់ប្តូរពីវ័យជំទង់រហូតដល់ដើមមជ្ឈឹមវ័យ។

ពេញមួយការសិក្សាថ្នាក់វិទ្យាល័យ ការទទួលខុសត្រូវលើសុខុមាលភាពផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗគឺអាស្រ័យទៅលើគ្រូណែនាំរបស់ពួកគេ។ គ្រូណែនាំមានទំនាក់ទំនងយ៉ាងរឹងមាំជាមួយសិស្សានុសិស្ស និងបញ្ហានានាដែលអាចប៉ះពាល់ដល់វឌ្ឍនភាពនិងសុខុមាលភាពរបស់ពួកគេ។ ពួកគេចំណាយពេលជាមួយសិស្សានុសិស្សពេញមួយសប្តាហ៍ ដោយផ្តល់ឱ្យពួកគេនូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីផលប្រយោជន៍បុគ្គល ស្ថានភាពផ្ទាល់ខ្លួន ភាពខ្លាំង ភាពខ្សោយ និងប្រវត្តិនៃការសិក្សា។

សិស្សានុសិស្សនៅវិទ្យាល័យត្រូវបានលើកទឹកចិត្តឱ្យបន្តការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពក្រៅកម្មវិធីសិក្សាជាច្រើនដែលត្រូវបានផ្តល់ដល់សម្រាប់ពួកគេ។ វាមានសារៈសំខាន់ខ្លាំងណាស់ដែលយុវវ័យរក្សាបាននូវតុល្យភាពជីវិតការងារមួយដ៏ល្អ ជាពិសេសនៅក្នុងឆ្នាំចុងក្រោយនៃការអប់រំកម្រិតមធ្យមសិក្សារបស់ពួកគេ។

បន្ថែមពីលើ VCE យើងក៏ផ្តល់ជូននូវកម្មវិធីត្រៀមចូលថ្នាក់ឧត្តមសិក្សារបស់អង្គការបាក់កាឡូរេអាអន្តរជាតិ ( IBDP ) ដែលជាកម្មវិធីត្រៀងចូលថ្នាក់ឧត្តមសិក្សាដែលត្រូវបានគោរពបំផុតនិងទទួលស្គាល់យ៉ាងទូលំទូលាយដោយបណ្ដាសាកលវិទ្យាល័យឈានមុខរបស់ពិភពលោក។ មហាវិទ្យាល័យ សឺន លេអូណាដស៍ គឺជាសាលារៀនទីមួយរបស់រដ្ឋវិចតូរីយ៉ា ( ១៩៨២ ) និងជាសាលារៀនទីពីរនៅប្រទេសអូស្ត្រាលីដែលមានដាក់បញ្ចូលកម្មវិធី IBDP នេះ។ ចាប់តាំងពីពេលនោះមក កម្មវិធីនេះទទួលបានប្រជាប្រិយភាពកាន់តែខ្លាំងឡើង ដោយមួយឆ្នាំៗ ជាងមួយភាគបីនៃសិស្សឆ្នាំទី ១២ របស់យើងបានជ្រើសរើសយកកម្មវិធី IBDP ជាមាគ៌ាដែលគេពេញចិត្ត ឆ្ពោះទៅកាន់ថ្នាក់ឧត្តមសិក្សា។ ជម្រើសមុខវិជ្ជាទូលំទូលាយ ព្រមជាមួយបុគ្គលិកមានសមត្ថភាពនិងការតាំងចិត្តខ្ពស់ដែលកំពុងបង្រៀនទាំងនៅក្នុងកម្មវិធី VCE និង IBDP ធានាថា សិស្សានុសិស្សរបស់យើងនឹងទទួលបាននូវការបង្ហាត់បង្រៀននិងការគាំទ្រល្អបំផុតដែលអាចទទួលបាន។